**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាភ្នំពេញនៅព្រះសហគមន៍សន្តយ៉ូសែបផ្សារតូច**
**ថ្ងៃទី២១ កញ្ញា ២០១៧**

អត្ថបទទី១៖អភ ៩,១-៧.១១-១៣
ដំណឹងល្អ៖មថ ៩,៩-១៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងនឹករឮកដល់បងប្អូនយើង ដល់មនុស្សដែលយើងស្គាល់ និងមិនស្គាល់ ដែលបានទទួលមរណភាព ដល់វិញ្ញាណក្ខន្ធរបស់គេ។ នេះជាឱកាសមួយសម្រាប់យើងជាគ្រីស្តបរិស័ទ ដើម្បីបង្ហាញអំពីជំនឿរបស់យើងដែលមានលើព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ។ តាមពិត នៅពេលយើងនិយាយអំពីសេចក្តីស្លាប់ នៅពេលយើងនិយាយអំពីបងប្អូនដែលទទួលមរណភាព យើងដឹងភ្លាមថានៅពេលនោះយើងនឹកឃើញដល់ពេលព្រះយេស៊ូដែលសោយទីវង្គតដែរ។ ដោយពេលព្រះយេស៊ូសោយទីវង្គត បីថ្ងៃក្រោយមកព្រះយេស៊ូមានជីវិតថ្មី និងជីវិតថ្មីនេះជាជីវិតដ៏រុងរឿងជាជីវិតអស់កល្បជានិច្ច ណែនាំឲ្យពីពេលនោះពិភពលោកមានសេចក្តីសង្ឃឹមថ្មីតែម្តង។ ណែនាំឲ្យយើងយល់ថា មនុស្សដែលស្លាប់មិនមែនទីបញ្ចប់នៃដំណើរជីវិត ប៉ុន្តែជាដំណាក់កាលមួយនៅក្នុងជីវិតរបស់យើង ដោយសារជីវិតរបស់យើងនៅបន្តទៀតជាមួយព្រះជាម្ចាស់ ក្នុងរបៀបមួយដែលយើងមិនទាន់ស្គាល់ នៅក្នុងរបៀបមួយដែលយើងមិនដឹង ព្រះយេស៊ូមិនដែលពន្យល់យើងយ៉ាងច្បាស់។ ប៉ុន្តែ យើងដឹងថាយើងកំពុងនៅជាមួយព្រះយេស៊ូអស់កល្បជានិច្ច ដោយសារព្រះជាម្ចាស់បានណែនាំឲ្យព្រះយេស៊ូឈរឡើងពីចំណោមអ្នកស្លាប់ទាំងអស់ ដើម្បីទទួលសិរីរុងរឿង និងដើម្បីទទួលជីវិតអស់កល្បជានិច្ច។ ហេតុនេះហើយ នៅពេលយើងនឹកឃើញដល់មរណភាព យើងទោះបីជាពិបាកចិត្តក៏ដោយ ទោះបីយើងឈឺចិត្តដោយសារយើងបាត់មនុស្សម្នាក់ដែលយើងស្រឡាញ់ ដោយសារយើងបាត់មនុស្សម្នាក់ដែលយើងធ្លាប់មានទំនាក់ទំនងជាមួយគ្នាជាយូរឆ្នាំ។ ប៉ុន្តែយើងដឹងថាជាឱកាសមួយ ដើម្បីបង្ហាញអំពីជំនឿរបស់យើង និងអំពីសេចក្តីសង្ឃឹមរបស់យើងផង។

ពីម្សិលមិញ យើងបានគោរពមរណសាក្សីនៅប្រទេសកូរ៉េ។ នៅប្រទេសកូរ៉េ មានបងប្អូនគ្រីស្តបរិស័ទរាប់ម៉ឺននាក់ ដែលបានទទួលមរណភាពនៅសម័យ សតវត្សទី១៩ និងគេបៀតបៀនគ្រីស្តបរិស័ទ ដោយសាររដ្ឋអំណាចស្អប់ជំនឿរបស់យើង។ នៅពេលនោះគ្រី

ស្តបរិស័ទមានជម្រើស គឺជ្រើសរើសបន្តធ្វើដំណើរនៅលើផែនដីនេះឬស្លាប់តែម្តង ដោយសាររដ្ឋអំណាចចាប់គេ និងណែនាំឲ្យគេបោកប្រាស់ថា "យើងលែងជឿលើព្រះយេស៊ូ យើងស្អប់ព្រះយេស៊ូ យើងស្អប់ព្រះសហគមន៍ យើងស្អប់ព្រះជាម្ចាស់"។ ប៉ុន្តែមានជនជាតិកូរ៉េរាប់ម៉ឺននាក់ ដែលមិនសុខចិត្តបដិសេធនឹងជំនឿដែលគេបានទទួលពីពិធីជ្រមុជទឹកមក និងសុខចិត្តស្លាប់ដោយថា "មិនមែនទេ ខ្ញុំជឿលើព្រះយេស៊ូ ខ្ញុំមានជំនឿលើព្រះសហគមន៍ ខ្ញុំមិនចង់បដិសេធនឹងជំនឿដែលខ្ញុំបានទទួល" ហើយនៅពេលនោះគេបោកក្បាលនឹងថ្ម ហើយសម្លាប់គេរាប់ម៉ឺននាក់។ នៅពេលគ្រីស្តបរិស័ទឆ្លើយតបទៅរដ្ឋអំណាចដែលកំពុងកាត់ក្តីគេអំពីជំនឿរបស់គេ "ខ្ញុំមានជំនឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ" នៅពេលនោះគេបង្ហាញ៖ ទីមួយ) អំពីជំនឿ និងទីពីរ) អំពីសេចក្តីសង្ឃឹម។ ដោយសារគេដឹងថាទោះបីគេស្លាប់ មានន័យថាអស់មួយជីវិតនៅលើផែនដីនេះ ជីវិតរបស់គេមិនឈប់ទេ ជីវិតរបស់គេបន្តទៀតនៅជាមួយព្រះជាម្ចាស់ ដោយសារនេះជាសេចក្តីសង្ឃឹមរបស់យើង។

ហេតុនេះហើយ ថ្ងៃនេះដែលយើងគោរពវិញ្ញាណក្ខន្ធ ដល់បងប្អូនដែលទទួលមរណភាព ជាឱកាសមួយសម្រាប់យើងជាព្រះសហគមន៍ សម្រាប់យើងដែលជាគ្រីស្តបរិស័ទដើម្បីនឹកឃើញ៖ ទីមួយ) ដល់ជំនឿរបស់យើង យើងប្រកាសរាល់អាទិត្យ ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពិតមែនព្រះយេស៊ូណែនាំឲ្យយើងមានជីវិតអស់កល្បជានិច្ច។ ប៉ុន្តែកុំឲ្យសេចក្តីប្រកាសនេះ ចេញតែពីបបូរមាត់យើងតែប៉ុណ្ណឹង ប៉ុន្តែជាជំនឿ ជាមូលដ្ឋាននៃជំនឿ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញពិតមែន និងជំនឿនេះណែនាំឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច។ ដោយសារ យើងដឹងថាជីវិតរបស់យើងនឹងបញ្ឈប់នៅលើផែនដីនេះ ប៉ុន្តែយើងបន្តធ្វើដំណើរជាមួយព្រះយេស៊ូ ជាមួយព្រះជាម្ចាស់ដែលទទួលស្វាគមន៍យើង ដូចដែលយើងបានគោរពព្រះនាងម៉ារីឡើងស្ថានបរមសុខអាទិត្យមុន។ ព្រះនាងម៉ារីបានចូលទៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់អស់កល្បជានិច្ច ដោយសារព្រះនាងម៉ារីនៅលើផែនដីនេះបានជាប់ជាមួយព្រះជាម្ចាស់អស់ហើយ។

យើងបានស្តាប់ក្នុងអត្ថបទទីមួយ **ព្រះជាម្ចាស់ជាព្រះនៃយើង យើងបានផ្ញើរជីវិតលើព្រះអង្គ ហើយព្រះអង្គបានសង្គ្រោះយើង។យើងបានផ្ញើរជីវិតលើព្រះជាអម្ចាស់មែនចូរយើងសប្បាយរីករាយ មានអំណរឡើង ត្បិតព្រះអង្គបានសង្គ្រោះយើង។** ហើយពេលយើងនិយាយអំពីព្រះអង្គសង្គ្រោះយើង យើងមិនគិតតែអំពីជីវិតនៅលើផែនដីនេះ ប៉ុន្តែយើងគិត

អំពីជីវិតនៅថ្ងៃអនាគត។ យើងហ៊ាននិយាយអំពីអនាគត ដោយសារអនាគតរបស់យើងមិនមែននៅលើផែនដីនេះ ប៉ុន្តែអនាគតរបស់យើងនៅស្ថានបរមសុខរួមជាមួយព្រះជាម្ចាស់។

នៅថ្ងៃនេះ យើងអរគុណព្រះជាម្ចាស់សម្រាប់មនុស្សទាំងអស់ ដែលបានទទួលមរណភាពឲ្យគេបានរកឃើញសេចក្ដីសង្ឃឹម នៅក្នុងស្ថានបរមសុខជាមួយព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ។

ថ្ងៃនេះក៏ជាឱកាស ដែលយើងនឹកឃើញដែរអំពីយើងរៀងៗខ្លួន ប្រហែលយើងមានសុខភាពល្អ ប្រហែលយើងមានអាយុក្មេង ប្រហែលយើងមានកម្លាំងពេញខ្លួន។ ប៉ុន្តែម្ដងៗ យើងត្រូវការនឹកឃើញ ជីវិតរបស់យើងមិនមែនអស់កល្បជានិច្ចនៅលើផែនដីនេះ។ ម្ដងៗ យើងត្រូវការនឹកឃើញជីវិតរបស់យើងត្រូវការបញ្ចប់ដែរ មានន័យថាម្ដងៗយើងត្រូវការនឹកឃើញថ្ងៃណាមួយយើងស្លាប់ដែរ យើងស្លាប់ដូចមនុស្សទាំងអស់ និងយើងត្រូវការរៀបចំខ្លួនដើម្បីទទួលមរណភាព។ ទោះបីយើងនៅក្មេង ទោះបីយើងមានសុខភាពនៅល្អក៏ដោយ យើងត្រូវការត្រៀមខ្លួនជានិច្ចដើម្បីអី? ដើម្បីបង្ហាញខ្លួននៅមុខតុលាការរបស់ព្រះជាម្ចាស់។ ដូចយើងបានស្ដាប់នៅក្នុងអត្ថបទទីពីរហើយ "**ត្បិតដូចយើងមានជីវិតរស់យ៉ាងណា មនុស្សទាំងអស់ ពិតជាលុតជង្គង់ថ្វាយបង្គំយើង ហើយប្រកាសទទួលស្គាល់ព្រះជាម្ចាស់យ៉ាងនោះដែរ**"។ ដូច្នេះ យើងត្រូវរៀបរាប់ទូលព្រះជាម្ចាស់នូវអំពើដែលខ្លួនយើងម្នាក់ៗបានប្រព្រឹត្ត។ ហើយនេះជាអ្វីដែលសំខាន់សម្រាប់ជីវិតរបស់យើង! ចាប់ពីពេលនេះតទៅ យើងត្រូវការត្រៀមខ្លួនជានិច្ចដូចយើងបានស្ដាប់នៅក្នុងអត្ថបទគម្ពីរដំណឹងល្អ "**ចូរប្រុងប្រៀបខ្លួន ហើយទុកឲ្យចង្កៀងអ្នករាល់គ្នានៅឆេះ**"។ ពិតមែនជីវិតរបស់មានកំណត់ អាយុជីវិតរបស់យើងមានកំណត់ ថ្ងៃយើងមិនស្គាល់ ម៉ោងយើងមិនដឹង ឆ្នាំយើងមិនដឹង។ ប៉ុន្តែយើងដឹងថា នៅថ្ងៃណាមួយយើងនៅមុខព្រះជាម្ចាស់។ ព្រះសហគមន៍និយាយអំពី ការវិនិច្ឆ័យចុងក្រោយ និយាយអំពីតុលាការរបស់ព្រះជាម្ចាស់ ហើយនៅពេលនោះព្រះជាម្ចាស់ពិនិត្យមើល តែមិនពិនិត្យមើលអីច្រើនប៉ុន្មានទេ ប៉ុន្តែពិនិត្យមើលអី?

បងប្អូនជាទីស្រឡាញ់! ពិនិត្យមើលសេចក្ដីស្រឡាញ់ ដែលយើងមានចំពោះបងប្អូនឯទៀតៗ ដែលមានចំពោះព្រះសហគមន៍ ដែលយើងមានចំពោះពិភពលោកទាំងមូល។ ហើយនៅពេលនោះ ដូចយើងបានស្ដាប់ "ដូច្នេះយើងត្រូវរៀបរាប់ទូលព្រះជាម្ចាស់ នូវអំពើ

ដែលខ្លួនយើងម្នាក់ៗបានប្រព្រឹត្ត"។ យើងត្រូវការបង្ហាញអំពីអ្វីៗទាំងអស់ដែលយើងបានប្រព្រឹត្ត។

ប្រសិនបើបងប្អូនបានចាប់អារម្មណ៍អំពីព័ត៌មានមួយអាទិត្យ ពីរអាទិត្យកន្លងមក យើងបានឃើញសេចក្តីស្លាប់ មិនមែនអ្វីដែលយើងអាចត្រៀមខ្លួនជានិច្ច ពេលយើងចាស់ជរា ពេលយើងមានជំងឺយ៉ាងធ្ងន់ យើងដឹងថាចូលដំណាក់កាលយើងហើយ។ ប៉ុន្តែប្រសិនបើយើងមើលព័ត៌មាពិភពលោកពីប៉ុន្មានថ្ងៃកន្លងមក មានមនុស្សច្រើនដែលស្លាប់ ក៏ប៉ុន្តែយើងមិនដឹងមុន កាលពីខែមុននៅប្រទេសម៉ិកស៊ិក្ក មានរាប់ពាន់អ្នកដែលស្លាប់ដោយសាររញ្ជួយដី ណែនាំឲ្យគេមិនដឹងទេ ព្រឹកឡើងភ្ញាក់គេឃើញដីកំពុងញ័រនិងអាគារធ្លាក់ និងមានគេស្លាប់ និងមានសាលាមួយកូនក្មេងកំពុងរៀនស្លាប់អស់ហើយ។ ប្រសិនបើបងប្អូនបានចាប់អារម្មណ៍នៅភូមា ពីប៉ុន្មានថ្ងៃមានជនជាតិ គេហៅជនជាតិ រ៉ូហ៊ីញ៉ា ហ្គាស ដែលជាអ៊ីស្លាមដែលរស់នៅក្នុងភូមា គេកំពុងបណ្តេញគេទៅបង់ក្លាដេស នៅក្នុងប៉ុន្មានអាទិត្យ ពីរអាទិត្យ បីអាទិត្យ មានសែសិបម៉ឺននាក់ដែលកំពុងធ្វើដំណើរដើម្បីទៅប្រទេសបង់ក្លាដេសដែលជាប្រទេសទីពីររបស់គេដោយសារប្រទេសកំណើតរបស់គេគឺភូមា និងនៅក្នុងសែសិបម៉ឺននាក់មានរាប់ពាន់នាក់ដែលស្លាប់ហើយ ប៉ុន្តែគេអត់ទាន់បានត្រៀមខ្លួន គេអត់ដឹងថាថ្ងៃស្អែកយើងត្រូវការស្លាប់ ដោយសារមានគេសម្លាប់យើង មានកូនក្មេងច្រើន មានចាស់ជរាច្រើន គេអត់ទាន់ត្រៀមខ្លួនដោយសារមិនទាន់ដល់ពេលវាលា មិនដល់អាយុរបស់គេ។ ពីប៉ុន្មានថ្ងៃ ប្រសិនបើមើលព័ត៌មានយើងឃើញដែរ មានព្យុះ នៅខាងកោះនៅជិតសហរដ្ឋអាមេរិក ដែលណែនាំឲ្យបំផ្លាញអាគារអស់រលីងមានមនុស្សប៉ុន្មាននាក់ដែលស្លាប់ដែរ ប៉ុន្តែអត់មាននរណាដឹងទុកជាមុនយើងនឹងស្លាប់។ ហេតុនេះហើយ សម្រាប់ជីវិតរបស់យើងដែលមើលមិនឃើញ ដែលមិនទៀងទាត់ ដោយសារយើងអត់ដឹងថ្ងៃស្អែកមានអីខ្លះត្រូវកើតឡើង។ ប៉ុន្តែសម្រាប់ជីវិតរបស់យើង យើងត្រូវការត្រៀមខ្លួនជានិច្ច។ និងព្រះបន្ទូលដែលយើងស្តាប់ពីព្រះយេស៊ូថ្ងៃនេះសំខាន់ណាស់ "ចូរប្រុងប្រៀបខ្លួន ហើយទុកឲ្យចង្កៀងអ្នករាល់គ្នានៅឆេះ" នេះជាជីវិតរបស់យើង ធ្វើយ៉ាងម៉េចដើម្បីឲ្យពន្លឺនៃជំនឿ ពន្លឺនៃសេចក្តីសង្ឃឹម និងពន្លឺនៃធម៌មេត្តាករុណា អាចភ្លឺជានិច្ចនៅក្នុងខ្លួនរបស់យើង។

ជាឱកាសមួយដើម្បីនៅពេលនេះទូលអង្វរព្រះជម្ចាស់សារជាថ្មី សូមព្រះអង្គប្រទានឲ្យយើងមានជំនឿរឹងមាំ សូមព្រះអង្គប្រទានព្រះអំណោយទានមួយយ៉ាងពិសេស ឲ្យខ្ញុំជឿ

លើព្រះជាម្ចាស់ពិត ដោយអធិដ្ឋានជានិច្ច ដោយយកចិត្តទុកដាក់ចូលអភិបូជា យកចិត្តទុកដាក់ទទួលអគ្គសញ្ញានានា។ នេះជាឱកាសមួយ ដើម្បីសូមឲ្យជំនឿរបស់យើងរឹងមាំថែមទៀត ដោយសារយើងដឹងហើយ ជំនឿជាអំណោយទាន ជាអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់ផ្ទាល់ និងជំនឿនេះឲ្យវារឹងមាំ កុំឲ្យជំនឿរបស់យើងបន្តិចម្តងៗសាបទៅៗ យើងត្រូវតែសុំគ្រប់ពេលវេលា "ឱព្រះជាម្ចាស់អើយ! សូមប្រទានជំនឿឲ្យខ្ញុំ ឲ្យខ្ញុំរឹងមាំដូចមរណ-សាក្សីពីដើម ឲ្យខ្ញុំរឹងមាំដូចគ្រីស្តបរិស័ទពីដើម ឲ្យខ្ញុំហ៊ានប្រកាសនៅក្នុងគ្រប់កាលៈទេសៈ ពិតមែនខ្ញុំជាគ្រីស្តបរិស័ទ ដោយជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ឲ្យខ្ញុំរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ ដូចព្រះនាងម៉ារីបានភ្ជាប់ជាមួយព្រះជាម្ចាស់យ៉ាងជិតស្និទ្ធបំផុត។

ឆ្នាំនេះដែលយើងប្រារព្ធ២៥ឆ្នាំនៃព្រះសហគមន៍របស់យើង នៅសន្តយ៉ូសែបនេះ ជាឱកាសមួយដើម្បីសុំឲ្យព្រះករុណាទិគុណរបស់ព្រះជាម្ចាស់យាងមក យាងចូលនៅក្នុងខ្លួនរបស់យើងដើម្បីឲ្យយើងមានជំនឿរឹងមាំថែមទៀត ឲ្យយើងនឹករឭកដល់គ្រីសបរិស័ទពីដើមដែលបានយកចិត្តទុកដាក់អធិដ្ឋានជានិច្ចនៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង ឲ្យនឹករឭកដល់គ្រីស្តបរិស័ទពីដើម ដែលបានចាប់ផ្តើមឲ្យព្រះសហគមន៍របស់យើងនៅទីនេះរស់ឡើងវិញ២៥ឆ្នាំមុនដោយថែរក្សាជំនឿរបស់គេនៅក្នុងភាពងងឹតនៃជីវិតដែរ។

ដូច្នេះឆ្នាំនេះជាឱកាសមួយដើម្បីឲ្យជំនឿរបស់យើងរឹងមាំថែមទៀត ដោយប្រកាសថា ពិតមែនព្រះយេស៊ូជាជីវិត ពិតមែនព្រះយេស៊ូគង់នៅជាមួយខ្ញុំ ខ្ញុំលែងខ្លាចអី ដោយសារខ្ញុំជឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញមែន។ ជាឱកាសមួយដែរដើម្បីប្រកាសអំពីសេចក្តីសង្ឃឹមរបស់យើង ដោយសារយើងជាគ្រីស្តបរិស័ទ អតតសញ្ញាណរបស់យើងគឺប្រជារាស្ត្រនៃក្តីសង្ឃឹម។ យើងជាប្រជារាស្ត្រនៃក្តីសង្ឃឹម យើងត្រូវតែសម្លឹងមើលគ្រីស្តបរិស័ទពីដើម ពីសន្តសិលាដែលបានប្រកាស "ខ្ញុំជឿលើព្រះយេស៊ូ ពិតមែនព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់" ឲ្យយើងបន្តប្រកាសជំនឿរបស់យើងលើព្រះយេស៊ូ ដូចសន្តសិលាពីដើមរហូតដល់សព្វថ្ងៃដោយសារសេចក្តីសង្ឃឹមណែនាំឲ្យយើងមានជីវិត និងសេចក្តីសង្ឃឹមណែនាំឲ្យព្រះសហគមន៍របស់យើងស្ថិតស្ថេររហូត។ យើងជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម ឲ្យយើងថែរក្សាអត្តសញ្ញាណរបស់យើងជានិច្ច។

និងនៅក្នុងពេលនេះជាឱកាសមួយដែរ ដើម្បីបង្ហាញអំពីធម៌មេត្តាករុណាជានិច្ច ដោយសារដូចខ្ញុំនិយាយអំបាញ់មិញ នៅពេលដែលយើងជួបជាមួយព្រះជាម្ចាស់ផ្ទាល់ព្រះជាម្ចាស់មានសំណួរតែមួយ "តើយើងមានបានស្រឡាញ់មនុស្សម្នាក់? តើយើងមានបានយកចិត្តទុកដាក់ដើម្បីបង្ហាញធម៌មេត្តាករុណាដូចម្ដេច?

យើងត្រូវការនឹកឃើញអំពីរបៀបដែល ព្រះយេស៊ូនិយាយប្រស្នាទាក់ទងទៅនឹងការវិនិច្ឆ័យចុងក្រោយនៃពិភពលោក។ នៅពេលនោះព្រះយេស៊ូនិយាយអី? នៅពេលខ្ញុំឈឺ នៅពេលខ្ញុំអត់មានសំលៀកបំពាក់ នៅពេលខ្ញុំកំពុងស្រេកឃ្លាន នៅពេលខ្ញុំជាប់មន្ទីរឃុំឃាំង នៅពេលខ្ញុំនៅម្នាក់ឯង តើបានសួរសុខទុក្ខខ្ញុំទេឬ? នេះជាសំណួរដែលមានសម្រាប់យើងទាំងអស់ កុំឲ្យយើងគិតវែងឆ្ងាយ ឲ្យយើងឃើញគ្រប់អំពើដែលយើងបានប្រព្រឹត្ត យើងត្រូវតែរៀបរាប់នៅមុខព្រះជាម្ចាស់ ដើម្បីបង្ហាញអំពីសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ដែលយើងបានណែនាំបងប្អូនឯទៀតៗជានិច្ច។

ដូច្នេះនៅពេលនេះនេះជាឱកាសមួយ ដើម្បីសូមព្រះជាម្ចាស់ជួយយើង ឲ្យយើងយកចិត្តទុកដាក់ ឲ្យទឹកត្រជាក់មួយកែវដល់បងប្អូនឯទៀតៗជាប្រចាំថ្ងៃនៅក្នុងជីវិតរបស់យើង។ ប៉ុន្មានថ្ងៃមុននៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ព្រះសហគមន៍យើងបានចែកអង្ករ ចែកម្ហូបអាហារដល់អ្នកក្រីក្រ។ ប៉ុន្តែនេះមិនទាន់ល្មមទេ ដោយសារនេះជាព្រះសហគមន៍ដែលធ្វើ ជាគណៈកម្មការសង្គហៈដែលធ្វើ ជាតំណាងនៃព្រះសហគមន៍យើងដែលធ្វើ។ ប៉ុន្តែថ្ងៃនេះ ជាឱកាសមួយដើម្បីយើងរៀងៗខ្លួន គិតផ្ទាល់ខ្លួន "ខ្ញុំបានធ្វើអីខ្លះសម្រាប់អ្នកក្រីក្រម្នាក់? ខ្ញុំបានធ្វើអីខ្លះដើម្បីមនុស្សម្នាក់ដែលកំពុងរងទុក្ខលំបាក?" កុះភ្លេចពាក្យប្រស្នា តែមិនមែនពាក្យប្រស្នា ជាពាក្យពិតរបស់ម្ដាយតេរេសា សន្តីម្ដាយតេរេសា។ ប៉ុន្តែម្ដាយតេរេសាបាននិយាយថា "ប្រសិនបើយើងជួយមួយរយនាក់ ពីពាន់នាក់ មួយម៉ឺននាក់មិនបានទេអត់អីទេ! សំខាន់យ៉ាងតិចឲ្យយើងជួយម្នាក់" យ៉ាងតិចឲ្យយើងយកចិត្តទុកដាក់ជួយម្នាក់។

ដូច្នេះ ដើម្បីត្រៀមខ្លួនជានិច្ច ដើម្បីរៀបចំចិត្តគំនិតរបស់យើងទទួលព្រះយេស៊ូយាងមកនៅក្នុងជីវិតរបស់យើង ឲ្យយើងយកចិត្តទុកដាក់ ជួយម្នាក់ មនុស្សម្នាក់ ដើម្បីឲ្យគាត់មានសង្ឃឹមមានសេចក្ដីសង្ឃឹមនៅក្នុងជីវិតរបស់គាត់។ យើងដឹងហើយនៅក្នុងជំនាញយើងនៅក្នុងចំណោមយើង នៅក្នុងព្រះសហគមន៍យើងផង នៅក្នុងសង្គមរបស់យើងផង នៅ

កន្លែងដែលយើងរស់នៅជាប្រចាំ មិនខ្វះមនុស្សដែលគ្មានទីពឹង គ្មានសេចក្តីសង្ឃឹម។ មិនខ្វះសោះ ហើយខ្ញុំជឿថាមានច្រើនទៅៗ អត់ត្រូវការទៅដល់ភូមា អត់ត្រូវការទៅដល់ឆ្ងាយៗ ប៉ុន្តែនៅក្នុងប្រទេសរបស់យើងអស់ហើយ ឲ្យយើងបន្តបើកភ្នែក ហើយត្រូវនឹកថា នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ សម្តែងធម៌មេត្តាករុណាជានិច្ច។

ដូច្នេះថ្ងៃនេះ ពិតមែនយើងមានអំណរសប្បាយ។ យើងមានអំណរសប្បាយដោយសារអ្វី? ដោយសារព្រះយេស៊ូមានព្រះបន្ទូល "ពេលម្ចាស់ត្រឡប់មកឃើញអ្នកបម្រើណានៅរង់ចាំលោក អ្នកបម្រើនោះមានសុភមង្គលហើយ!"។ ថ្ងៃនេះយើងមានសុភមង្គលហើយដោយសារអ្វី? ដោយសារយើងដឹងថា យើងយកចិត្តទុកដាក់បម្រើបងប្អូនឯទៀតៗ យើងយកចិត្តទុកដាក់បង្ហាញធម៌មេត្តាករុណាជានិច្ច យើងយកចិត្តទុកដាក់អធិដ្ឋានដើម្បីរៀបចំខ្លួនទទួលព្រះយេស៊ូជានិច្ចដូចព្រះនាងម៉ារី។ ដូចព្រះនាងម៉ារី ដោយយើងរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ជានិច្ច។

ដូច្នេះថ្ងៃនេះ មិនមែនថ្ងៃដែលយើងតែងទុក្ខព្រួយ ដែលយើងពិបាកចិត្ត ប៉ុន្តែជាថ្ងៃដែលយើងដឹងថា ព្រះយេស៊ូគង់នៅជាមួយយើង ព្រះយេស៊ូណែនាំឲ្យយើងទៅជាអ្នកបម្រើពោរពេញដោយសុភមង្គលដ៏ពិតប្រាកដ។ ពិតមែនថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ យើងទូលអង្វរព្រះអង្គ សូមព្រះអង្គទទួលវិញ្ញាណក្ខន្ធរបស់បងប្អូនយើងទាំងអស់ដែលបានទទួលមរណភាព ឲ្យរស់នៅក្នុងសេចក្តីសង្ឃឹមរបស់ព្រះជាម្ចាស់ និងឲ្យយើងបន្តរៀបចំខ្លួន។ យើងជាក្មេងក៏ដោយ យើងជាចាស់ក៏ដោយ យើងមានសុខភាពល្អក្តី យើងមានជំងឺក្តី យើងត្រូវតែត្រៀមខ្លួន ត្រៀមខ្លួនជានិច្ច ដើម្បីបង្ហាញយើងរៀបចំខ្លួនហើយ ដើម្បីទទួលព្រះយេស៊ូ ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូដែលកំពុងយាងមក។ យើងនៅស្ងៀមស្ងាត់ ដោយទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គបំភ្លឺយើងថែមទៀត ដើម្បីឲ្យជំនឿរបស់យើងរឹងមាំ ដើម្បីឲ្យសេចក្តីសង្ឃឹមរបស់យើងទៅជាសេចក្តីសង្ឃឹមយ៉ាងសកម្ម ដើម្បីឲ្យសេចក្តីស្រឡាញ់របស់យើង ទៅជាសេចក្តីស្រឡាញ់ដែលប្រព្រឹត្តអំពើល្អជានិច្ចសម្រាប់បងប្អូនឯទៀតៗនៅក្នុងនាមព្រះយេស៊ូគ្រីស្ត។ អាម៉ែន៕